**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៧១០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្វាយលើ ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.៧១០ ( ប្រាំពីរពាន់ ប្រាំពីររយដប់ ) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ និងដំណាំកសិឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកាលេខ ០២៣ ខសរ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ របស់សាលាខេត្តសៀមរាប ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ផែនទី បង្ហាញពីដីកាត់ពន្លូកចេញពីតំបន់ស្នើសុំសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លី យ៉េ វ៉ាប់ប៊ីរ ខូអិលធីឌី

## ស្ថិតក្នុងឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប




និយាមកាចំណុចគោល

| POINT | COOR_X | COOR_Y |
|---|---|---|
| A | 438626 | 1507035 |
| B | 427988 | 1509042 |
| C | 428000 | 1513000 |
| D | 430000 | 1513000 |
| E | 430028 | 1520027 |
| F | 434872 | 1523427 |

និយាមកាចំណុច ដីកាត់

| Name | COOR_X | COOR_Y |
|---|---|---|
| a | 432033 | 1517408 |
| b | 431038 | 1517408 |
| c | 431085 | 1518914 |
| d | 432032 | 1518914 |
| e | 431545 | 1508401 |
| f | 430644 | 1511905 |
| g | 430625 | 1513638 |
| h | 431424 | 1513638 |
| i | 431425 | 1511918 |
| j | 432298 | 1508626 |
| k | 431229 | 1518914 |
| l | 431229 | 1520370 |
| m | 432526 | 1521495 |
| n | 433930 | 1521463 |
| o | 434246 | 1521263 |
| p | 433971 | 1520355 |
| q | 434653 | 1519051 |
| r | 433609 | 1518309 |
| s | 433296 | 1518863 |
| t | 432288 | 1518222 |
| u | 432032 | 1518220 |
| v | 435641 | 1518205 |
| w | 436164 | 1518179 |
| x | 436396 | 1518682 |
| y | 436299 | 1519319 |
| z | 436523 | 1519501 |

សញ្ញាសំគាល់

- ចំណុចគោល — តំបន់ស្នើសុំ ៧ ៧១០ ហ.ត — គម្របព្រៃឈើ ឆ្នាំ២០០៦
- ចំណុចកាត់ចេញ — តំបន់ទ្រនាប់ ៦៤៥ ហ.ត — ព្រៃស្រោង : ១ ៩៥៧ ហ.ត
- ព្រំប្រទល់ខេត្ត — តំបន់ព្រៃការពារ ៨៣៥ ហ.ត — ព្រៃពាក់កណ្តាលស្រោង : ២ ៦៧៨ ហ.ត
- ព្រំប្រទល់ឃុំ — ដីអភិវឌ្ឍន៍សហគមន៍ស្រុក ១៥០ ហ.ត — ព្រៃល្បោះ : ៨ ៣៦១ ហ.ត
- ផ្លូវ — ដីកសិកម្ម ៣៨៦ ហ.ត — ដីគ្មានគំរបព្រៃ : ៣៣ ហ.ត
- ផ្លូវទឹក

- ដីផ្លូវ និងប្រាសាទបុរាណ: ៣១៥ ហ.ត
- ដីពាក់ព័ន្ធប្រជាពលរដ្ឋ: ២ ៥១៨ ហ.ត

សរុប ១២ ៦៦៩ ហ.ត

ផ្ទៃដីមិនកាត់ព័ន្ធ :

សរុបផ្ទៃដីកាត់ព័ន្ធ ៤ ៩៥៩ ហ.ត  ១២ ៦៦៩ ហ.ត - ៤ ៩៥៩ ហ.ត = ៧ ៧១០ ហ.ត




មាត្រដ្ឋាន1:100,000
0 3
Kilometers

លេខ ១៤/... 
បានឃើញ និង គោរពជូនលោក
អភិបាលស្រុកមេគ្នាកិច្ចី និងសម្រេច
ស្វាយលើ,ថ្ងៃទី 17 ខែ ... ឆ្នាំ ២០១១
ប្រធានការិយាល័យកសិកម្មស្រុកស្វាយលើ

លេខ .../១១ ...
បានឃើញ និង គោរពជូនលោក
អភិបាលស្រុកមេគ្នាកិច្ចី និងសម្រេច
... ថ្ងៃទី ... ខែ 12 ឆ្នាំ ២០១១
ឌុំ រិន

លេខ ... ល.ស.ស.
បានឃើញ និង គោរពជូនឯកឧត្តម
អភិបាលខេត្តមេគ្នាកិច្ចី និងសម្រេច
ស្វាយលើ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
អភិបាលស្រុកស្វាយលើ
ហៅ សែន

លេខ ...
បានឃើញ និង គោរពជូនលោក
អភិបាលស្រុកមេគ្នាកិច្ចី និងសម្រេច
ស្វាយលើ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
ប្រធានការិយាល័យរៀបចំដែនដីស្រុកស្វាយលើ

លេខ ... សរសស
បានឃើញ និង គោរពជូនឯកឧត្តម
អភិបាលខេត្តមេគ្នាកិច្ចី និងសម្រេច
សៀមរាប,ថ្ងៃទី ... ខែមករា ឆ្នាំ ២០១២
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ សៀមរាប
សែ សារុត

លេខ ... ...
បានឃើញ និង គោរពជូនឯកឧត្តម
អភិបាលខេត្តមេគ្នាកិច្ចី និងសម្រេច
សៀមរាប,ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
ប្រធានមន្ទីរកសិកម្មខេត្តសៀមរាប
ស៊ឿង ស៊ីហ្សា

លេខ ...
បានឃើញ និង ឯកភាព
សៀមរាប,ថ្ងៃទី ... ខែ ... ឆ្នាំ ២០១...
អភិបាលខេត្ត
ស៊ូ ភិរិន្ទ